# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតអបអរសាទរ

## សូមគោរពជូន

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ក្នុងឱកាសទទួលបាន សញ្ញាបត្របណ្ឌិតកិត្តិយស ពីសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ**

**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏ថ្លៃថ្លាប្រកបដោយក្តីសោមនស្សរីករាយ ដែល **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** ទទួលបាន **សញ្ញាបត្របណ្ឌិតកិត្តិយស ពីសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ** ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ ពិតជាមានសេចក្តីរីករាយបាយរីករាយឥតឧបមា និងសូមសម្តែងនូវអំណរសាទរអស់ពីដួងចិត្ត ជូនចំពោះ **សម្តេចក្រឡាហោម** ដែល **សម្តេច** ទទួលបានសញ្ញាបត្របណ្ឌិតកិត្តិយសដ៏ថ្លៃថ្លានេះ។

ការទទួលបាន **សញ្ញាបត្របណ្ឌិតកិត្តិយស** នេះ ពិតជាស័ក្តិសមនឹងគុណធម៌ ប្រាជ្ញាស្មារតី និងភាពប៉ិនប្រសប់របស់ **សម្តេចក្រឡាហោម** ក្នុងភារកិច្ចចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយបានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ដើម្បីបុព្វហេតុជាតិ ពុះពារដឹកនាំស្តារ កសាង និងអភិវឌ្ឍមាតុភូមិកម្ពុជាតាំងតែពីប្រទេសជាតិបានរស់ឡើងវិញក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ មកដល់សព្វថ្ងៃ ដោយធានាបាននូវសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងប្រជាធិបតេយ្យនៅកម្ពុជា រួមចំណែកយ៉ាងសំខាន់ធ្វើឱ្យប្រទេសមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងច្រើនឥតគណនាលើគ្រប់វិស័យ ក៏ដូចជាសេចក្តីសុខក្សេមក្សាន្តរបស់ប្រជាជនកម្ពុជាទូទៅក្នុងរយៈពេលកន្លងមករហូតដល់បច្ចុប្បន្ននេះ។

ក្នុងឱកាសប្រកបដោយក្តីរីករាយនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមតាមបីបាច់ថែរក្សា **សម្តេចក្រឡាហោម និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តចូលរួមចំណែកដឹកនាំរាជរដ្ឋាភិបាលកម្ពុជា កសាងមាតុភូមិកម្ពុជាឱ្យកាន់តែឈានឆ្ពោះទៅការរីកចម្រើនបន្ថែមទៀត ដើម្បីភាពសម្បូរសប្បាយរុងរឿង និងសុភមង្គលរបស់ប្រជាជនកម្ពុជាជានិច្ចនិរន្តរ៍តរៀងទៅ ជាពិសេស សូមជួបប្រទះពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃពុធ ១១រោច ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh